ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធ
ប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)
អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

លេខាធិការដ្ឋានរដ្ឋបាលសរុប

## កំណត់បង្ហាញលិខិតចូល

**ក្រសួង ស្ថាប័ន** ៖ ក្រសួងយុត្តិធម៌ លេខ ០១០៣ កយ.អយព្រ/២៤ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៤។

**ខ្លឹមសារលិខិត** ៖ សំណើសុំចាត់ តំណាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ០២រូប ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្ដីពីការតាមដាន និងរាយការណ៍នៃកម្មវិធី អាស៊ាន-អូស្ត្រាលី ប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT)។ សិក្ខាសាលាពិគ្រោះយោបល់នេះនឹងប្រព្រឹត្តទៅនៅថ្ងៃទី ៦-៧ ខែកុម្ភៈ ឆ្នាំ២០២៤ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។

**យោបល់** ៖ គោរពជូន លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត អគ្គលេខាធិការ មេត្តាពិនិត្យ និងជូនជ្រាបដោយក្ដីគោរព។

- គួរសុំការអនុញ្ញាតយកលិខិតនេះដើម្បីគោរពជម្រាបជូន **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។

ថ្ងៃ.អង្គារ.១៣.កើត.ខែ...បុស្ស...ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី ...២៣... ខែ.មករា... ឆ្នាំ២០២៤

ជ. **ប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប**

ឧត្ដមសេនីយ៍ទោ. ថោង_វុទ្ធី

**យោបល់ លោកជំទាវ អគ្គលេខាធិការ**

- [illegible]
- [illegible]
- [illegible]

ឧត្ដមសេនីយ៍ឯក វេជ្ជ.ប៊ុណ្ណា សំខាន់ 26/01/2024

**យោបល់ ឯកឧត្ដម អគ្គលេខាធិការរងទទួលបន្ទុក**

- [illegible]
- [illegible]

23/01/2024

ឧត្ដមសេនីយ៍ឯក.យ៉េម_ច័ន្ទណារុំ

**យោបល់ លោកជំទាវរដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

- [illegible]
- [illegible]

[illegible] 26/01/24

ជ. ប៊ិនអេក

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
ចូល
លេខ: ០១៩/២៤
ថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០២៤
បញ្ជូនមកពី.........

លេខ : ០១០៣ កយ.អឃបត្រ/២៤ ថ្ងៃ អង្គារ ៦កើត ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**សូមជម្រាបជូន**

**លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជា**
**អនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**កម្មវត្ថុ៖** សំណើសុំចាត់ តំណាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្ដីពីការតាមដាន និងរាយការណ៍នៃកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស(ASEAN-ACT)។

**យោង ៖** លិខិត ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៣ របស់កម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT)។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោកជំទាវរដ្ឋលេខាធិការ** ជ្រាបថា ក្រសួងយុត្តិធម៌បានទទួលលិខិតរបស់កម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស(ASEAN-ACT) ដែលមានកម្មវត្ថុស្នើសុំក្រសួងយុត្តិធម៌ជួយសម្របសម្រួលអញ្ជើញ តំណាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ២ រូប ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្ដីពីការតាមដាន និងរាយការណ៍នៃកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស(ASEAN-ACT)។ សិក្ខាសាលាពិគ្រោះយោបល់នេះនឹងប្រព្រឹត្តទៅនៅថ្ងៃទី៦-៧ ខែកុម្ភៈ ឆ្នាំ២០២៤ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។

អាស្រ័យហេតុនេះ សូម **លោកជំទាវរដ្ឋលេខាធិការ** ចាត់តំណាង ចំនួន ២ រូប ដើម្បីចូលរួមសិក្ខាសាលាពិគ្រោះយោបល់ខាងលើកុំបីខាន។

សូម **លោកជំទាវរដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

-សូមផ្ដល់ព័ត៌មានអ្នកចូលរួមតាមរយៈ៖
កញ្ញា រឹម វ៉ាណែត
លេខទូរស័ព្ទ ០៧៧ ៦៨៦ ៦៦២
-ឯកសារ កាលប្បវត្តិ

Australian Aid | ASEAN-Australia Counter Trafficking

No.1 Vasu1 Building,
Office 801, Sukhumvit 25,
Klongtoey-Nua, Wattana,
Bangkok 10110 Thailand
Tel +66 2 259 4311
info@aseanact.org
aseanact.org

ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០២៣

**សូមគោរពជូន**
**ឯកឧត្តម កើត រិទ្ធ**
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**
**នៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ:** សំណើស្នើសូមអនុញ្ញាតសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការតាមដាន និងរាយការណ៍នៃកម្មវិធីនៃកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT)។

សេចក្តីដូចបានគោរពស្នើសូម ឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាពិនិត្យលទ្ធភាពអនុញ្ញាតរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការតាមដាន និងរាយការណ៍នៃកម្មវិធីនៃកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT) ដែលគ្រោងធ្វើនៅថ្ងៃទី៦ និង ទី៧ ខែកុម្ភៈ ឆ្នាំ២០២៤។ គោលបំណងនៃកិច្ចប្រជុំនេះ មានដូចខាងក្រោម៖

- ធ្វើការពិគ្រោះយោបល់ជាមួយអ្នកចូលរួមអំពីការតាមដាន និងការរាយការណ៍នៃដំណាក់កាលទី ២ នៃកម្មវិធី ASEAN-ACT។
- ផ្តល់ព័ត៌មានជូនដល់អ្នកចូលរួមអំពីផែនការសម្រាប់ការតាមដាន ការវាយតម្លៃ និងការរៀនសូត្រ (MEL) នៃដំណាក់កាលទី ២ នៃកម្មវិធី ASEAN-ACT។

យើងខ្ញុំសូមគោរពជម្រាបជូន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាជ្រាបថា ឯកឧត្តម ប៉ែន ពេជ្រសាលី ប្រតិភូរាជរដ្ឋាភិបាល អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ និងជាប្រធានក្រុមការងារបច្ចេកទេសនៃកម្មវិធីអាស៊ាន-អូស្ត្រាលីប្រចាំកម្ពុជា (NPSC) បានផ្តល់អនុសាសន៍ឲ្យកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT) រៀបចំ

សិក្ខាសាលានៅបណ្ឌិតសភាភូមិន្ទយុត្តិធម៌កម្ពុជា (ប.ភ.យ.ក.)។ កម្មវិធី ASEAN-ACT សូមអរគុណចំពោះអនុសាសន៍នេះ និងរីករាយក្នុងការជំរុញកិច្ចសហការជាមួយ ប.ភ.យ.ក.។

ជាការឆ្លើយតបទៅនឹងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌** កម្មវិធី ASEAN-ACT បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីដំណាក់កាលទីពីរនៃ កម្មវិធី ASEAN-ACT នៅ ប.ភ.យ.ក. នៅថ្ងៃទី ៧ និង ៨ ខែកញ្ញា ឆ្នាំ ២០២៣។ តម្លៃសរុបនៃអ្នកចូលរួមមួយនាក់នៅ ប.ភ.យ.ក. គឺ **៥៥,៨១ ដុល្លារអាមេរិក** ធៀបទៅនឹងតម្លៃ*មធ្យម*ក្នុងមួយនាក់ **២៦,០០ ដុល្លារអាមេរិក** នៅសណ្ឋាគារកាំបូឌីយ៉ាណា ឬសណ្ឋាគារភ្នំពេញ។ យើងខ្ញុំសូមគោរពបង្ហាញភ្ជាប់ជូនតារាងប្រៀបធៀបចំណាយលម្អិតនៃសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីដំណាក់កាលទីពីរនៃកម្មវិធី ASEAN-ACT នៅ ប.ភ.យ.ក. និងចំណាយលម្អិតនៃសិក្ខាសាលាស្តីពីតុលាការដែលយកចិត្តទុកដាក់ចំពោះជនរងគ្រោះ ដែលបានប្រព្រឹត្តទៅ នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២ នៅសណ្ឋាគារកាំបូឌីយ៉ាណា ដើម្បីគោរពជូនជ្រាបជាព័ត៌មានដ៏ខ្ពង់ខ្ពស់ជូន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាជ្រាប។

បន្ថែមលើថ្លៃចំណាយខ្ពស់ អ្នកចូលរួមសិក្ខាសាលាប្រហែល ៣០ ភាគរយ ដែលមកពីក្រសួង/ស្ថាប័នពាក់ព័ន្ធផ្សេងៗ បានផ្តល់មតិថាទីតាំង ប.ភ.យ.ក. គឺមានលក្ខណៈលំបាកដោយសារចម្ងាយផ្លូវឆ្ងាយបន្តិចពីកណ្តាលរាជធានីភ្នំពេញ។

អាស្រ័យហេតុនេះ ដើម្បីធានាអនុលោមភាពនឹងគោលការណ៍ប្រសិទ្ធភាពចំណាយ (value for money) នៃកម្មវិធី ASEAN-ACT និងដើម្បីជួយសម្រួលការចូលរួមពេញលេញរបស់សិក្ខាកាម យើងខ្ញុំសូមគោរពស្នើសូមរៀបចំដំណើរការសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការតាមដាន និងរាយការណ៍នៃកម្មវិធីនៃកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT) នៅសណ្ឋាគារកាំបូឌីយ៉ាណា។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម ឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាពិនិត្យនិងសម្រេចអនុញ្ញាតដំណើរការសិក្ខាសាលា និងទីកន្លែងសិក្ខាសាលាដូចបានគោរពជម្រាបជូនខាងលើ ដោយសេចក្តីអនុគ្រោះ។

ជាទីបញ្ចប់ នាងខ្ញុំសូមឆ្លៀតយកឱកាសនេះដើម្បីថ្លែងអំណរគុណចំពោះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ចំពោះកិច្ចសហប្រតិបត្តិការដ៏រឹងមាំ និងការគាំទ្ររបស់ក្រសួងយុត្តិធម៌ចំពោះកម្មវិធី ASEAN-ACT និងសង្ឃឹមបន្តកិច្ចសហការកាន់តែជិតស្និទ្ធថែមទៀត។

សូម ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីនាងខ្ញុំ។

*[ហត្ថលេខា]*

Lucia Pietropaoli

ប្រធានក្រុម

កម្មវិធី ASEAN-ACT

**ចម្លងជូន:** - ឯកឧត្តម ប៉ែន ពេជ្រសាលី ប្រតិភូរាជរដ្ឋាភិបាល, អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ និងជាប្រធានក្រុមការងារបច្ចេកទេសនៃកម្មវិធីអាស៊ាន -អូស្ត្រាលីប្រចាំកម្ពុជា (NPSC)។

ឯកសារជូនភ្ជាប់: - តារាងប្រៀបធៀបតម្លៃ
- របៀបវារៈព្រាង (ខេមរភាសា និង អង់គ្លេស)
- បញ្ជីគ្រោងអញ្ជើញក្រសួងឬស្ថាប័នចូលរួម

**ទំនាក់ទំនង:** កញ្ញា ហេង ម៉ូលិកា មន្ត្រីគាំទ្រគម្រោង ASEAN-ACT។ ទូរស័ព្ទ: ០១៥ ៣៦៥ ១០៥

សិក្ខាសាលាពិគ្រោះយោបល់ស្តីពីការតាមដាន និងរាយការណ៍នៃកម្មវិធីនៃកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT)

កាលបរិច្ឆេទ: ថ្ងៃទី ៦ និង ៧ ខែកុម្ភៈ ឆ្នាំ២០២៤

បញ្ជីស្ថាប័នចូលរួម

| ល.រ | ស្ថាប័ន | ចំនួនអ្នកចូលរួម | ផ្សេងៗ |
|---|---|---|---|
| 1 | គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | 2 | |
| 2 | ក្រសួងយុត្តិធម៌ | 2 | |
| 3 | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 2 | |
| 4 | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 2 | |
| 5 | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | 1 | |
| 6 | ក្រសួងកិច្ចការនារី | 1 | |
| 7 | ក្រសួងអប់រំ យុវជន និងកីឡា | 1 | |
| 8 | អគ្គស្នងការដ្ឋាននគរបាលជាតិ | 1 | |
| 9 | នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន | 2 | |
| 10 | នាយកដ្ឋានអន្តោប្រវេសន៍ | 1 | |
| 11 | SOMTC កម្ពុជា | 2 | |
| | *សរុប* | 17 | |
| | **ស្ថាប័នអង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាល** | | |
| 14 | អង្គការពលកម្មពិភពលោក (ILO) | 1 | |
| 15 | អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) | 1 | |
| 16 | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) | 1 | |
| 17 | អង្គការរតនៈអន្តរជាតិ | 1 | |
| 18 | Winrock International | 1 | |
| 19 | អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) | 1 | |
| 20 | អង្គការ Agape International Missions (AIM) | 1 | |
| 21 | អង្គការ A 21 | 1 | |
| 22 | អង្គការ Hagar International Foundation | 1 | |
| 23 | អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី (LSCW) | 1 | |
| 24 | អង្គារសម្ព័ន្ធភាពចាប់ដៃ | 1 | |
| 25 | អង្គការ APLE | 1 | |
| 26 | អង្គការ Caritas កម្ពុជា | 1 | |

| | | |
|---|---|---|
| 27 | អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) | 1 |
| 28 | អង្គការក្តីសង្ឃឹមយុត្តិធម៌ (Hope for Justice) | 1 |
| 29 | អង្គការ Central | 1 |
| 30 | អង្គការ ADHOC | 1 |
| | *សរុប* | **17** |
| | សរុបរួម | **34** |

**Consultation Workshop on Monitoring and Reporting**
**Date: 6-7 February 2024**
**List of participants**

| # | Institutions | Number of Participants | Comments |
|---|---|---|---|
| 1 | National Committee for Counter Trafficking (NCCT) | 2 | |
| 2 | Ministry of Justice (MoJ) | 2 | |
| 3 | Ministry of Social Affairs Veterans and Youth Rehabilitation (MoSVY) | 2 | |
| 4 | Ministry of Labour and Vocational Training (MoLVT) | 2 | |
| 5 | Ministry of Foreign Affairs and International Cooperation (MoFAIC) | 1 | |
| 6 | Ministry of Women's Affairs (MoWA) | 1 | |
| 7 | Ministry of Education Youth and Sport (MoEYS) | 1 | |
| 8 | Cambodian National Police (CNP) | 1 | |
| 9 | Department of Anti-Human Trafficking and Juvenile Protection (DAHTJP) | 2 | |
| 10 | Department of Immigration | 1 | |
| 11 | SOMTC Cambodia | 2 | |
| | ***Sub-total-1*** | 17 | |
| | **UN Agency/INGOs/NGOs** | | |
| 14 | International Labour Organisation (ILO) | 1 | |
| 15 | International Organization for Migration (IOM) | 1 | |
| 16 | United Nations Development Programme (UNDP) | 1 | |
| 17 | Ratanak International | 1 | |
| 18 | Winrock International | 1 | |
| 19 | International Justice Mission | 1 | |
| 20 | Agape International Missions (AIM) | 1 | |
| 21 | A 21 | 1 | |
| 22 | Hagar International Foundation | 1 | |
| 23 | LSCW | 1 | |
| 24 | Chab Dai Coalition | 1 | |
| 25 | APLE | 1 | |
| 26 | Caritas Cambodia | 1 | |
| 27 | Gender and Development for Cambodia (GADC) | 1 | |
| 28 | Hope for Justice | 1 | |
| 29 | Central | 1 | |
| 30 | ADHOC | 1 | |
| | ***Sub-total-2*** | 17 | |
| | **Total** | **34** | |

# របៀបវារៈ

Australian Aid | ASEAN-Australia Counter Trafficking

| | |
|---|---|
| **ចំណងជើង** | សិក្ខាសាលាពិគ្រោះយោបល់ស្តីពីការតាមដាន និងការវាយការណ៍ |
| **ទីកន្លែង** | សណ្ឋាគារកាំបូឌីយ៉ាណា (បញ្ជាក់នៅពេលក្រោយ) |
| **កាលបរិច្ឆេទ** | ថ្ងៃទី ៦-៧ ខែកុម្ភៈ ឆ្នាំ២០២៤ |
| **អ្នកចូលរួមគោលដៅ** | • តំណាងវិស័យយុត្តិធម៌: មន្ត្រីទទួលបន្ទុកការងារតាមដាន និងវាយការណ៍អំពីកិច្ចប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់រដ្ឋាភិបាល<br>• តំណាងវិស័យផ្សេងពីយុត្តិធម៌ និង អង្គការមិនមែនរដ្ឋាភិបាល: ការងារតាមដាន និងវាយការណ៍នៅក្នុងស្ថាប័នឬអង្គការ |

**គោលបំណង៖**

- ធ្វើការពិគ្រោះយោបល់អំពីការតាមដាន និងវាយការណ៍នៃកម្មវិធី ASEAN-ACT ដំណាក់កាលទី ២
- ចែករំលែកព័ត៌មានអំពីការអភិវឌ្ឍផែនការតាមដាន វាយតម្លៃ និងរៀនសូត្រ (MEL) នៃដំណាក់កាលទី ២ ។

| វគ្គ | ម៉ោង | ថ្ងៃទី ១ ថ្ងៃអង្គារ | អ្នកសម្របសម្រួល |
|---|---|---|---|
| | ០៨:០០ | ចុះឈ្មោះ | |
| ១ | ០៨:៣០ – ០៩:០០ | ▪ ពិធីបើកសិក្ខាសាលា និងមតិស្វាគមន៍<br>➢ ណែនាំអំពីគោលបំណងនៃសិក្ខាសាលា | នាយកគ្រប់គ្រងប្រចាំប្រទេស |
| ២ | ០៩:០០ – ១០:១៥ | ▪ បទបង្ហាញស្តីពីទ្រឹស្តីនៃការប្រែប្រួល (ឬឯកសារមូលដ្ឋាននៃកម្មវិធី) នៃកម្មវិធី ASEAN-ACT<br>➢ ណែនាំគោលគំនិតមូលដ្ឋាននៃការតាមដាន និងវាយតម្លៃ<br>➢ បង្ហាញទ្រឹស្តីនៃការប្រែប្រួល (ឬឯកសារមូលដ្ឋាននៃកម្មវិធី) ដែលបានកែសម្រួលនៃកម្មវិធី<br>➢ សំណួរ និងចម្លើយ | ក្រុមការងារ MEL |
| | ១០:១៥– ១០:៣០ | សម្រាក (១៥ នាទី) | |
| ៣ | ១០:៣០ – ១២:០០ | ▪ គោលបំណងនៃក្របខ័ណ្ឌ MEL<br>➢ បទបង្ហាញ៖ តើអ្វីជាក្របខ័ណ្ឌ MEL?<br>➢ ការពិភាក្សាជាក្រុម | ក្រុមការងារ MEL |
| | ១២:០០– ១៣:០០ | អាហារថ្ងៃត្រង់ (១ ម៉ោង) | |

| វគ្គ | ម៉ោង | ថ្ងៃទី ១ ថ្ងៃអង្គារ | អ្នកសម្របសម្រួល |
|---|---|---|---|
| ៤ | ១៣:០០ – ១៥:០០ | ▪ ការតាមដាននិងការរាយការណ៍ថ្នាក់ជាតិអំពីការជួញដូរមនុស្ស<br>➢ បទបង្ហាញដោយតំណាង/អ្នកចូលរួមជាជម្រើសមួយចំនួន ឬការពិភាក្សាវាគ្មិនឯកទេស<br>➢ សំណួរ និងចម្លើយ និងការពិភាក្សាបើកទូលាយ | ក្រុមការងារ MEL និងក្រុមការងារប្រចាំប្រទេស |
| | ១៥:០០– ១៥:១៥ | សម្រាក (១៥ នាទី) | |
| | ១៥:១៥ – ១៦:៣០ | បន្តការពិភាក្សាបើកទូលាយ | ក្រុមការងារ MEL |
| | ១៦:៣០ | ចប់ថ្ងៃទី ១<br>ការជួបប្រជុំវាយតម្លៃរបស់ក្រុមអ្នកសម្របសម្រួល | |

| វគ្គ | ម៉ោង | ថ្ងៃទី ២ ថ្ងៃពុធ | អ្នកសម្របសម្រួល |
|---|---|---|---|
| | ០៨:០០– ០៩:០០ | ចុះឈ្មោះ | |
| ៥ | ០៨:៣០ – ០៩:០០ | រំឭកសង្ខេបថ្ងៃទី ១ និងរបៀបវារៈនៃថ្ងៃទី ២ | ក្រុមការងារប្រចាំប្រទេស |
| ៦ | ០៩:០០ – ១០:០០ | ▪ រង្វាស់ជោគជ័យ<br>➢ បទបង្ហាញ៖ រង្វាស់ជោគជ័យ និងសូចនាករ<br>➢ ទិន្នន័យបែងចែកតាមសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI) និងសូចនាករទាក់ទិននឹងសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI)<br>➢ ការពិភាក្សាជាក្រុម | ក្រុមការងារ MEL |
| | ១០:០០– ១០:១៥ | សម្រាក (១៥ នាទី) | |
| ៦ (ត) | ១០:១៥ – ១២:០០ | ▪ បន្តវគ្គទី ៦ – បទបង្ហាញក្រុមជូនអង្គប្រជុំរួម | ក្រុមការងារ MEL និង ក្រុមការងារប្រចាំប្រទេស |
| | ១២:០០– ១៣:០០ | អាហារថ្ងៃត្រង់ (១ ម៉ោង) | |
| ៧ | ១៣:០០ – ១៥:១៥ | ▪ ការរាយការណ៍ ការឆ្លុះបញ្ចាំង និងការរៀនសូត្រ<br>➢ បទបង្ហាញ៖ ការរាយការណ៍ ការឆ្លុះបញ្ចាំង និងការរៀនសូត្រ<br>➢ ការពិភាក្សាជាក្រុម<br>➢ ការធ្វើបទបង្ហាញជាក្រុម | ក្រុមការងារ MEL |

| វគ្គ | ម៉ោង | ថ្ងៃទី ២ ថ្ងៃពុធ | អ្នកសម្របសម្រួល |
|---|---|---|---|
| | ១៥:១៥– ១៥:៣០ | សម្រាក (១៥ នាទី) | |
| ៨ | ១៥:៣០ – ១៦:០០ | ▪ បិទសិក្ខាសាលា | អ្នកចូលរួមទាំងអស់ |
| | ១៦:៣០ | ចប់សិក្ខាសាលា<br>ការជួបប្រជុំវាយតម្លៃរបស់ក្រុមអ្នកសម្របសម្រួល | |

# AGENDA

Australian Aid | ASEAN-Australia Counter Trafficking

Draft V3 – 23 November 2023

| | |
|---|---|
| **Title** | Monitoring and reporting workshop |
| **Location** | Cambodiana Hotel (TBC) |
| **Date** | 6–7 February 2024 |
| **Target participants** | ▪ Justice sector representatives – officers involved in monitoring and reporting of counter–trafficking in persons efforts/initiatives of government<br>▪ Non-justice sector and NGO representatives – officers involved in monitoring and reporting within their agency or organisation |

Objectives:

- To conduct consultation on monitoring and reporting of ASEAN-ACT Phase 2.
- To inform the development of Phase 2 Monitoring, Evaluation and Learning Plan.

| Session | Time | Day 1 – Tuesday | Facilitator |
|---|---|---|---|
| | 08:00 | Arrival and registration | |
| 1 | 08:30 – 09:15 | ▪ Opening and welcoming remarks<br>▪ Introduction and objectives<br>➢ Introduce objectives and outline of the workshop | Country manager |
| 2 | 09:15 – 10:15 | ▪ Presentation on ASEAN-ACT theory of change<br>➢ Introduce basic M&E concepts<br>➢ Present the program's revised theory of change<br>➢ Q&A | MEL team |
| | 10:15 | BREAK (15 minutes) | |
| 3 | 10:30 – 12:00 | ▪ Purpose of MEL framework<br>➢ Presentation: What is a MEL framework?<br>➢ Group activity | MEL team |
| | 12:00 | LUNCH (1 hour) | |
| 4 | 13:00 – 15:00 | ▪ National-level monitoring and reporting on counter–trafficking in persons<br>➢ Selected participants/representatives presentations or panel discussions<br>➢ Q&A and open discussions | MEL team and country team |
| | 15:00 | BREAK (15 minutes) | |
| | 15:15 – 16:30 | ▪ Continue session 4 | MEL team and country team |
| | 16:30 | End of day 1<br>Facilitation team debrief | |

| Session | Time | Day 2 – Wednesday | Facilitator |
|---|---|---|---|

| | | | |
|---|---|---|---|
| | 08:00 | Arrival and registration | |
| 5 | 08:30 – 09:00 | Recap of Day 1 and outline of the day | Country team |
| 6 | 09:00 – 10:00 | ▪ Measure of success<br>➢ Presentation: measure of success and indicators<br>➢ GEDSI disaggregated data and GEDSI-related indicators<br>➢ Group activity | MEL team |
| | 10:00 | Break (15 minutes) | |
| 6 (cont.) | 10:15 – 12:00 | ▪ Session 6 Continue – Group presentation in plenary | MEL team and Country team |
| | 12:00 | Lunch (1 hour) | |
| 7 | 13:00 – 15:15 | ▪ Reporting, reflection and learning<br>➢ Presentation: reporting, reflection and learning<br>➢ Group activity<br>➢ Plenary group presentation | MEL team |
| | 15:15 | Break (15 minutes) | |
| 8 | 15:30 – 16:00 | ▪ Closing | All participants |
| | 16:00 | End of Workshop<br>Facilitation team debrief | |

តារាងប្រៀបធៀបតម្លៃចំណាយក្នុងមួយនាក់នៅ ប.ភ.យ.ក. និង តម្លៃចំណាយក្នុងមួយនាក់នៅសណ្ឋាគារកាំបូឌីយ៉ាណា

១. តម្លៃចំណាយក្នុងមួយនាក់នៅ ប.ភ.យ.ក.

ចំនួនអ្នកចូលរួមសុរប: ៨០ នាក់ (៤០ នាក់ x ២ ថ្ងៃ)

| មុខចំណាយ | ឯកតា | | តម្លៃឯកតា | តម្លៃសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| កញ្ចប់ប្រជុំថ្ងៃទី ១ (អាហារថ្ងៃត្រង់ កាហ្វេ) សម្រាប់អ្នកចូលរួម ៥០ នាក់ | 2 | ថ្ងៃ | $ 968.50 | $ 1,937.00 | |
| ជួលតុមូល និងកៅអី (តុ ៦ កៅ ៤៨) | 1 | ដង | $ 200.00 | $ 200.00 | |
| អ្នកឯកទេសអ៊ីនធឺណេត | 2 | ថ្ងៃ | $ 20.00 | $ 40.00 | |
| ផ្កា | 1 | ដង | $ 35.00 | $ 35.00 | |
| ប្រព័ន្ធសម្លេង | 2 | ថ្ងៃ | $ 140.00 | $ 280.00 | |
| បន្ទប់ប្រជុំ (ទំហំសម្រាប់ ៧០ នាក់) | 2 | day | $ 350.00 | $ 700.00 | |
| បន្ទប់ប្រជុំ (ទំហំសម្រាប់ ៣០ នាក់) សម្រាប់រៀបចំអាហាសម្រន់សម្រាប់អ្នកចូលរួម | 1 | day | $ 250.00 | $ 250.00 | គិតមួយថ្ងៃ |
| ពន្ធតម្លៃបន្ថែម (VAT) 15% លើថ្លៃសេវាជួលបន្ទប់ | 1 | time | $ 142.50 | $ 142.50 | |
| សរុប | | | | $ 3,584.50 | |
| ចំណាយក្នុងមួយនាក់ | | | | $ 44.81 | |

២. តម្លៃចំណាយក្នុងមួយនាក់នៅសណ្ឋាគារកាំបូឌីយ៉ាណា (២០ កញ្ញា ២០២២)

កញ្ចប់ប្រជុំពេញមួយថ្ងៃ ដោយមានអាហារសម្រន់ពីរពេល + អាហារថ្ងៃត្រង់មួយពេល
តម្លៃទាំងអស់រាប់បញ្ចូលសេវា ៥% និងពន្ធ

តម្លៃសរុប: ១.២៧២ ដុល្លារ
ចំនួនអ្នកចូលរួម: ៥៣ នាក់
តម្លៃក្នុងមួយនាក់: ២៤ ដុល្លារ

- ប្រើបន្ទប់ប្រជុំតាមសំណើ (ម៉ោង 8:00 – 17:00)

- បន្ទប់រៀបចំតាមសំណើ ដោយមានក្រដាសសរសេរ ខ្មៅដៃ និងស្ករគ្រាប់
- រៀបចំឆាកគណៈអធិបតីដោយមានផ្កាលម្អ
- អាហារសម្រន់ពេលព្រឹក រួមមាននំប្រាំមុខ ផ្លែឈើស្រស់ កាហ្វេ តែ ទឹកដោះគោឆៅ និង ទឹកផ្លែឈើ
- អាហារសម្រន់ពេលរសៀល រួមមាននំប្រាំមុខ ផ្លែឈើស្រស់ កាហ្វេ តែ ទឹកដោះគោឆៅ និង ទឹកផ្លែឈើ
- អាហារប៊ូហ្វេនៅភោជនីយដ្ឋានមេគង្គ
- តុចុះឈ្មោះនៅមាត់ទ្វារដោយមានផ្កាលម្អ
- LCD Projector ១ និងអេក្រង់
- ប្រព័ន្ធសម្លេង ជាមួយមីក្រូហ្វូនលើតុ ២ និងមីក្រូហ្វូនគ្មានខ្សែ ២
- ក្រដាសផ្ទាំងធំ ជាមួយហ្វឺតសរសេរ និងក្ដារខៀន
- ទឹកផឹក
- Wi-Fi ក្នុងអំឡុងពេលប្រជុំ

## Comparison of per head cost at RAJC and at the Cambodiana Hotel

### 1. Per head cost at the RAJC

**Number of participants: 80 (40 x 2 days)**

| Item | Unit | | Unit Cost | Total Cost | Comments |
|---|---|---|---|---|---|
| Meeting package day 1 (1 Lunch, 2 coffee breaks) for 40 participants | 2 | day | $ 968.50 | $ 1,937.50 | |
| Round table and chairs rental (6 tables, 48 chairs) | 1 | time | $ 200.00 | $ 200.00 | |
| Internet technician | 2 | day | $ 20.00 | $ 40.00 | |
| Flower | 1 | time | $ 35.00 | $ 35.00 | |
| Sound system | 2 | day | $ 140.00 | $ 280.00 | |
| Meeting room rental (Meeting room size 70 people) | 2 | day | $ 350.00 | $ 700.00 | |
| Meeting room rental (Meeting room size 30 people) for organize refreshment for participants | 1 | day | $ 250.00 | $ 250.00 | Only 1 day is charged |
| VAT 15% on service fee of meeting room rental | 1 | time | $ 142.50 | $ 142.50 | |
| **Total** | | | | **$ 3,584.50** | |
| **Cost per head** | | | | **$ 44.81** | |

### 1. Per head cost at the Cambodiana Hotel

**FULL DAY MEETING PACKAGE WITH TWO TIME COFFEE BREAKS + ONE LUNCH**
**All prices are included 5% service charge and applicable taxes**

**Total cost: US$1,272**
**Number of participants: 53**
**Per head cost: USD 24.00 net per person per day**

- Use of the meeting room as request time (8:00 – 17:00hrs)
- Room set up as per your requests with conference notepad, pencils and mints
- Head table set up on stage with flower arrangement
- Morning coffee break a selections of (5) items, fresh fruits, coffee, tea, milk and Chilled Fruit Juices
- Afternoon coffee break a selections of (5) items, fresh fruits, coffee, tea, milk and Chilled Fruit Juices
- One time set/Buffet lunch at Mekong restaurant
- Registration table at room entrance with standard flower arrangement
- Use of one (01) LCD Projector and Screen
- Use in-house sound system with (2) Conference microphones and (2) Wireless microphones
- Use (2) Flipcharts with makers and (2) white board
- Use Service Water / Filtered Tap Water in Water Dispensers
- Use of hotel standard Wi-Fi during the meeting